ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ១៥ (i) (ខែមករា ឆ្នាំ២០២០)

សាលដីកានេះអាចរកបាននូវ៖សាលដីកាតុ.កំពូលលេខ ១៥ (ឆបោក)

**ពាក្យគន្លឹះ៖** ឆបោក, រឿងកិច្ចសន្យា

## ១. អង្គហេតុនិងខ្លឹមសារសម្រេច

ក្នុងឆ្នាំ២០១៨ ជនត្រូវចោទ បានធ្វើសកម្មភាពជានាទិញ និងរត់ឯកសារទិញលក់ និងទទួលបានប្រាកមួយចំនួន។ កិច្ចសន្យា ត្រូវបានថតចម្លងមិនត្រឹមត្រូវតាមច្បាប់ដើម។ ជនត្រូវចោទ បានយកដីនោះទៅលក់ឲ្យអ្នកផ្សេងវិញ...។ អង្គហេតុនេះ ត្រូវបានចោទជាបទឆបោក តាមមាត្រា៣៧៧និង៣៧៨ នៃក្រមព្រហ្មទណ្ឌ។

ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលើកលែងចោទលេខ៤៨២ ខែមេសា ឆ្នាំ២០១៩ ។ ជនរងគ្រោះបានប្ដឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បាន តម្កល់ដីកាដំណោះស្រាយ (សាលដីកាលេខ២៧ ខែមេសា ឆ្នាំ២០១៩)។

តុលាការកំពូលបានពិនិត្យ និងស្ដាប់ការអះអាង យល់ឃើញថា....*គឺជាអង្គហេតុទាក់ទងនឹងការមិនគោរពកិច្ចសន្យាទិញលក់ដី* ដែលតុលាការអង្គសេចក្ដីបានធ្វើការពិនិត្យពិចារណាត្រឹមត្រូវតាមអង្គហេតុនិងគតិច្បាប់រួចហើយ។ ...ដើមបណ្ដឹងមិនមានភស្តុតាងបញ្ជាក់ពីការកិបកេង ដូចជាការប្រើល្បិច ឬមធ្យោបាយទុច្ចរិតដើម្បីឲ្យប្រគល់ប្រាក់ តែគ្មានដីលក់...*ការវិនិច្ឆ័យរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ មិនមានកំហុសក្នុងការអនុវត្តច្បាប់ទេ*។

### សម្រេច

**១**. បដិសេធបណ្ដឹងសាទុក្ខ...**២**. តម្កល់សាលដីកាលេខ២៧...។...

## ២. កំណត់សំគាល់

**ក.** ចាប់ពីថ្ងៃកើតហេតុមកដល់សវនាការនៅតុលាការកំពូល មានរយៈពេល២ឆ្នាំ។ គួរកត់សំគាល់ថា ដើមបណ្ដឹងអាចប្ដឹងឧទ្ធរណ៍និងប្ដឹងសាទុក្ខដល់តុលាការកំពូលប្រឆាំងនឹងដីកាដំណោះស្រាយ (closing order) លើកលែងចោទប្រកាន់។

**ខ.** តាមខ្លឹមសារនៃសាលដីកា តុលាការញែកបទឆបោកនិងការគ្រាន់តែរឿងបំពានកិច្ចសន្យា។ វាទាមទារនូវឧបាយកលទុច្ចរិត ទទួលបានអ្វីមួយ ក្រៅសកម្មភាពកិច្ចសន្យា នាំឲ្យជនរងគ្រោះខូចប្រយោជន៍ ដោយកិបកេង..។ តុលាការកំពូលបានជួយបំភ្លឺជាតុផ្សំនៃបទឆបោក។ សូមមើលសាលដីកាលេខ១០ ដែលមានខ្លឹមសារស្រដៀងគ្នា។